**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...០០៤...សហវ.......

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៣

# សេចក្តីសំរេច

**ស្តីពី**

**ការបង្កើតអង្គភាព រៀបចំ ការតាំងទីលំនៅឡើងវិញ**

**របស់ប្រជារាស្ត្រ ដោយសារគំរោងការកែលំអទីរួមខេត្ត-ក្រុង**

⊛ ⊛ ⊛

**ប្រធានគណៈកម្មការអន្តរក្រសួង**

**ដើម្បីធ្វើការវាយតម្លៃលើផលប៉ះពាល់ដល់សំណង់ផ្ទះសំបែង ដីធ្លី ប្រជារាស្ត្រ**

**ក្នុងគំរោងការកែលំអទីរួមខេត្ត-ក្រុង**

**យោង** :- ប្រកាសលេខ ៧៩៤ សហវ ប្រក របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការវាយតម្លៃលើផលប៉ះពាល់ដល់ សំណង់ ផ្ទះសម្បែង ដីធ្លី ប្រជារាស្ត្រ ក្នុងគំរោងការកែលំអទីរួមខេត្ត-ក្រុង ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០២ ។

## សំរេច

**ប្រការ ១** : បង្កើត អង្គភាព រៀបចំការតាំងទីលំនៅឡើងវិញ (Resettlement Unit) ដើម្បីធ្វើការវាយតម្លៃលើផលប៉ះពាល់ដល់ សំណង់ ផ្ទះសម្បែង ដីធ្លី ប្រជារាស្ត្រ ក្នុងគំរោងការកែលំអទីរួមខេត្ត-ក្រុង ។

**ប្រការ ២** : អង្គភាពនេះជាសេនាធិការផ្ទាល់របស់គណៈកម្មការអន្តរក្រសួង និង មានសមាសភាពដូចខាងក្រោម :

១. លោក **សំ ចរម** អនុប្រធាននាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធាន

២. លោក **ឡូ គុណធុទ្ធន៍** ប្រធានការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អនុប្រធាន

៣. លោក ឡេ ជុនហួរ ប្រធានមន្ទីរសាធារណការ និង ដឹកជញ្ជូន ក្រុងព្រះសីហនុ សមាជិក

៤. លោក ជូ ចាន់នី មន្ត្រីគំរោង ការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួយការ ទទួលបន្ទុកភ្ជាប់រួមក្រុមការងារ

៥. លោក នុយ ចាន់ណា មន្ត្រីគំរោង ការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួយការផ្នែកហិរញ្ញវត្ថុ

៦. លោកស្រី លឹម រតនកញ្ញា មន្ត្រីគំរោង ការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួយការ ផ្នែករដ្ឋបាល

**ប្រការ ៣ :** អង្គភាពនេះ មានភារកិច្ច ដូចខាងក្រោម :

-ចុះទៅពិនិត្យដល់ទីកន្លែង ធ្វើការ វាស់វែង អង្កេត លំអិត (DMS : Detailed Measurement Survey) លើផលប៉ះពាល់ ដល់ សំណង់ ផ្ទះសម្បែង ដីធ្លី ប្រជារាស្ត្រ នៅក្នុងគំរោងការកែលំអទីរួមខេត្ត-ក្រុង ។

-ប្រមូលទិន្នន័យរៀបចំជាផែនការ សកម្មភាព ការតាំងទីលំនៅឡើងវិញ (RAP : Resettlement Action Plan) ដើម្បីដាក់ជូនគណៈកម្មការអន្តរក្រសួងពិនិត្យ និង សំរេច មុននឹងផ្ញើជូនធនាគារអភិវឌ្ឍន៍អាស៊ី (ADB : Asian Development Bank) ពិនិត្យ និង អនុម័ត ។

-រៀបចំរបាយការណ៍ដាក់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ជាគោលការណ៍ លើផែនការ សកម្មភាព សំរាប់ការអនុវត្តន៍ ។

-ជាអ្នកទទួលបន្ទុកអនុវត្តដោយផ្ទាល់លើ ផែនការ សកម្មភាព ដែលបានទទួលការអនុម័តរួចហើយ ។

-រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំខែ ដាក់ជូនថ្នាក់ដឹកនាំគណៈកម្មការពិនិត្យ និង ផ្តល់ការណែនាំ ។

-រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំត្រីមាស , ប្រចាំឆមាស និង ប្រចាំឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និង ផ្តល់ការណែនាំ និង ដាក់ជូនបន្តទៅប្រមុខរាជរដ្ឋាភិបាល ជ្រាបជាពត៌មាន ។

**ប្រការ ៤ :** អង្គភាពសំរាប់រៀបចំការតាំងទីលំនៅឡើងវិញ អាចបង្កើតឡើងនូវក្រុមការងារតាមតំរូវការរបស់ខ្លួន ។

**ប្រការ ៥ :** ក្រសួង ស្ថាប័ន និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចប្រការ២ សូមផ្តល់កិច្ចសហប្រតិបត្តិការការងារដើម្បទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធិភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រធានគណៈកម្មការអន្តរក្រសួង

អនុរដ្ឋលេខាធិការ

ញ៉ាណ ឡេង

ចំលងជូន :

-សមាជិកគណៈកម្មការអន្តរក្រសួង

-ដូចប្រការ ៥

-ឯកសារ-កាលប្បវត្តិ